ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

TsIkarKN³rdm®nþI qaTI 2 elx ³ 4

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



Work Activities

ក ស វ

ប្រចាំខែ មេសា ឆ្នាំ ២០០៩



# matkaGtbT

## កិច្ចប្រជុំទី១ រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


ល.រ ឈ្មោះអត្ថបទ

១. សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ................. ១–២

២. សេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពី ការដាក់សារ និងរូបភាពព្រមានសុខភាពលើផលិតផលថ្នាំជក់ ........ ៣–៤

៣. សេចក្តីព្រាង កម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០–២០១២ ................................................................ ៥–៦

៤. សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ ............................ ៧

៥. សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ ................................................. ៨

៦. ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មីនា ឆ្នាំ ២០០៩ ......................................... ៩–១៣

៧. សកម្មភាពការងាររបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ........................................................ ១៤–១៧

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម

កាលពីថ្ងៃទី ០១ និង ២២ ខែ មេសា ឆ្នាំ ២០០៩ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិច ឈុន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.វ.ស.) និងឯកឧត្តម **យាង សេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការពាណិជ្ជកម្ម** ដោយមានការអញ្ជើញ ចូលរួមពីសំណាក់តំណាងក្រសួងពាណិជ្ជកម្ម សមាជិក អគ្គលេខាធិការ ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



ដើម្បីធ្វើឲ្យសម្រេចនូវការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ព្រមជាមួយនឹងការធ្វើកំណែទម្រង់ច្បាប់ រាជរដ្ឋាភិបាលបានយល់ព្រមរៀបចំសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យសំខាន់ៗជាច្រើន ដែលទាក់ទងទៅនឹងសកម្មភាពពាណិជ្ជកម្ម។ ដោយឡែក សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម គឺជាសកម្មភាពមួយទៀតនៃការអនុវត្តផែនការកែទម្រង់នេះផងដែរ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម ត្រូវបានតាក់តែងឡើងដោយឈរលើមូលដ្ឋានសំខាន់ៗមួយចំនួន ដូចជា៖ ១-ឯករាជ្យភាព និងអព្យាក្រឹតភាពពេញលេញ ២-មជ្ឈការអ្នកគ្រប់គ្រង និងបុគ្គលិកនៃមជ្ឈមណ្ឌលជាតិត្រូវមានគុណសម្បត្តិ និងមានសេចក្តីស្មោះត្រង់ ៣-ការចូលរួមដោយ ផ្ទាល់ពីផ្នែកឯកជនក្នុងការបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌល និង ៤-ការគាំទ្រដល់ប្រព័ន្ធតុលាការ។

សេចក្តីព្រាងអនុក្រឹត្យនេះមានសារៈសំខាន់បំផុតសម្រាប់ជម្រុញ និងអនុវត្តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដោយបង្កើតឡើងនូវមជ្ឈមណ្ឌលជាតិមួយ ដែលបម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចដូចខាងក្រោម៖

-ជំរុញវិស័យមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-កំណត់លក្ខណៈសម្បត្តិនៃបុគ្គលដែលមានបំណងចូលជាសមាជិកនៃមជ្ឈមណ្ឌលជាតិ

-ផ្តល់សេវាដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ

-ផ្តល់ការបណ្តុះបណ្តាល និងការហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្ត និងបុគ្គលដែលមានបំណងចង់អនុវត្តវិជ្ជាជីវៈ ជាមជ្ឈត្តករ ដើម្បីធានាឲ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នៅ-

ព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់

-ប្រមូល និងផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធទៅនឹង មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

-ឆ្លើយតបជាបន្ទាន់ទៅនឹងសំណូមពររបស់វិស័យឯកជនក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម តាមប្រព័ន្ធមជ្ឈត្តករថ្នាក់ជាតិមួយ ដែលមានលក្ខណៈឆាប់រហ័ស មាននីតិវិធីមិនស្មុគស្មាញ និងមានមជ្ឈត្តករដែលមានការយល់ដឹង និងមានបច្ចេកទេសច្បាស់លាស់ ដែលពិបាករកនៅក្នុងតុលាការ

-ឆ្លើយតបទៅនឹងលក្ខខណ្ឌដែលទាមទារនៅក្នុងកម្មវិធីសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ស្ថាប័នអន្តរជាតិមួយចំនួន ដូចជា អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងធនាគារអភិវឌ្ឍន៍ អាស៊ី(ADB)

សេចក្តីព្រាងអនុក្រឹត្យនេះមាន **៦ជំពូក** និង **៥៦មាត្រា**។



អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុលើ សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្ម។

## សេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពី

# ការដាក់សារ និងរូបភាពព្រមានសុខភាពលើផលិតផលថ្នាំជក់

កាលពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ វេលាម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **ឡាំ ជា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការដាក់សារ និងរូបភាពព្រមានសុខភាពលើផលិតផលថ្នាំជក់** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងសុខាភិបាល សមាជិក អគ្គលេខាធិការ ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។

នៅលើពិភពលោកទាំងមូល ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ការប្រើប្រាស់ផលិតផលថ្នាំជក់កាន់តែរីករាលដាលខ្លាំងឡើងៗ។ ការប្រើប្រាស់ផលិតផលថ្នាំជក់នេះ មិនត្រឹមតែមានផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ និងអ្នកស្រូបផ្សែងបារីពីអ្នកជក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច និងបរិស្ថានផងដែរ។ តាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកបានបង្ហាញឲ្យឃើញថា ថ្នាំជក់បានសម្លាប់មនុស្សប្រមាណ ៥.៤លាន ក្នុង ១ឆ្នាំ។ ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា អត្រាអ្នកជក់បារីក្នុងចំណោមមនុស្សពេញវ័យមានកម្រិតខ្ពស់។ តាមការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា អត្រាអ្នកជក់បារីក្នុងចំណោមមនុស្ស បុរសមានអាយុលើសពី ២០ឆ្នាំ មាន ៥៤ភាគរយ និងស្ត្រី ៦ភាគរយ។ ជារៀងរាល់ថ្ងៃមាន ៨០ភាគរយ នៃកុមារអាយុក្រោម ១៣ឆ្នាំ និងនារីបានស្រូបផ្សែងបារីពីអ្នកជក់បារីដែលរស់នៅក្នុងផ្ទះជាមួយ។ លទ្ធផលនៃការអង្កេតរបស់អង្គការលីដេរខ្មែរបានបង្ហាញឲ្យឃើញថា ក្នុងមួយឆ្នាំ ប្រទេសកម្ពុជាបានចំណាយថវិកាប្រហែល ៧០ លានដុល្លាអាមេរិក ក្នុងការទិញបារី ដោយមិនគិតពីការចំណាយថវិកាដែលបុគ្គល គ្រួសារ និងរដ្ឋ បានចំណាយសម្រាប់ព្យាបាលជម្ងឺបណ្តាលមកពីការជក់បារី ការបាត់បង់កម្លាំងពលកម្មសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច ការស្លាប់មុនអាយុ ការខាតបង់សេដ្ឋកិច្ច និងការខូចខាតបរិស្ថានបង្កឡើងដោយសារកាប្រើប្រាស់ថ្នាំជក់ នៅឡើយ។ ដើម្បីចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលឥតឈប់នូវការប្រើប្រាស់ថ្នាំជក់នេះ នៅឆ្នាំ ១៩៩៩ សភាសុខភាពពិភពលោកដែលមានប្រទេសចំនួន ១៩២ ជាសមាជិកបានផ្តួចផ្តើមគំនិតរៀបចំ អនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់។ ក្នុងនាមជាប្រទេសហត្ថលេខី នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ ព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចអនុវត្តការវេចខ្ចប់ និងការដាក់សាររូបភាពព្រមានសុខភាពលើផលិតផលថ្នាំជក់។



ឆ្លើយតបទៅនឹងបញ្ហាខាងលើ ក្រសួងសុខាភិបាល បានស្នើសុំដាក់ឆ្លងកិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពី ការដាក់សារ និងរូភាពព្រមានសុខភាពលើផលិតផលថ្នាំជក់ ដើម្បីជួយអប់រំផ្សព្វផ្សាយ

បង្កើនចំណេះដឹងដល់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ ទាំងអ្នកជក់បារី និងអ្នកដែលបានស្រូបផ្សែងបារី ដោយអចេតនា។

អង្គប្រជុំបានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពី ការដាក់សារ និងរូបភាពព្រមានសុខភាពលើផលិតផលថ្នាំជក់នេះ ហើយបានផ្តល់យោបល់ ដូចខាងក្រោម៖

-ពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់ សារាចរណែនាំនេះ មិនទាន់មានលក្ខណៈសមស្របទេ។

-សារាចរនេះមិនអាចអនុវត្តបានទេ ព្រោះបើគេមិនអនុវត្ត ក៏មិនមានទោសដែរ ដោយសារសារាចរនេះមិនមែនជាលិខិតបទដ្ឋាន មិនអាចចែងពីទោសប្បញ្ញត្តិបាន។

-គួររៀបចំជាអនុក្រឹត្យវិញ។



អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពី ការដាក់សារ និងរូបភាពព្រមានសុខភាពលើផលិតផលថ្នាំជក់។

## សេចក្ដីព្រាង

# កម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២



កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្ដម **តឹម សយសាម៉ាឡែន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្ដម **អ៊ុក ភូរិ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើ**សេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងផែនការ សមាជិក អគ្គលេខាធិការ ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្រសួងផែនការបានបញ្ចប់ការរៀបចំសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២ ហើយបានស្នើដាក់ប្រជុំឆ្លងនៅទីស្ដីការគណៈរដ្ឋមន្ត្រីឲ្យបានត្រឹមបំណាច់ ខែ មីនា ឆ្នាំ ២០០៩ ដើម្បីងាយស្រួលឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកទៅរៀបចំបន្តសម្រាប់ដាក់ប្រជុំជាមួយដៃគូអភិវឌ្ឍន៍ និងបញ្ចូលក្នុងថវិកាជាតិ។

ដោយសារការប្រើប្រាស់តួលេខមិនត្រូវគ្នា ដូច្នេះគេនឹងរៀបចំក្រុមការងារមួយដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ស្ថិតក្រោមការសម្របសម្រួលរបស់ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីឲ្យការងារប្រើប្រាស់តួលេខមានការឯកភាពគ្នានៅថ្ងៃក្រោយ។

គោលបំណងចំបងនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈគឺ ១-ឧបករណ៍គ្រប់គ្រងកម្មវិធី និងជាយន្តការសម្រាប់ធ្វើការកំណត់ និងចុះបញ្ជីគម្រោង ព្រមទាំងសកម្មភាពផ្សេងៗ ដើម្បីសម្រេចបានគោលដៅ និងចំណុចដៅតាមវិស័យជាច្រើន ដូចមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ២-មូលដ្ឋានគ្រឹះដើម្បីជួយគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា និងបណ្ដាក្រសួង ស្ថាប័នទាំងអស់ក្នុងការទាក់ទាញ និងតម្រង់ទិសដៃគូអភិវឌ្ឍន៍ក្នុងការផ្ដល់ជំនួយអភិវឌ្ឍកម្ពុជា តាមរយៈការកំណត់កម្មវិធី និងគម្រោងជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា (រាប់បញ្ចូលទាំងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីគៀគរជំនួយជារៀងរាល់ឆ្នាំ) ៣-យន្តការសម្រាប់ធ្វើការ



តម្រឹមតម្រង់ធនធានពីដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលដោយផ្ទាល់ទៅនឹងកម្មវិធីវិនិយោគនានាដែលជាអាទិភាពរបស់ជាតិ ចែងក្នុងផយអជ។ កម្មវិធីវិនិយោគសាធារណៈក៏ជាឧបករណ៍សម្រាប់ធ្វើការតាមដានត្រួតពិនិត្យវឌ្ឍនភាព នៃការតម្រឹមតម្រង់ធនធានសម្រាប់អភិវឌ្ឍកម្ពុជា។

កម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២ នេះត្រូវបានជ្រើសរើសគម្រោងចំនួន **៥៣៤** គម្រោង ដែលមាន **២៣៣** គម្រោង កំពុងដំណើរការ ដែលត្រូវការទុនចំនួន **១៩១៤** លានដុល្លារ និង **៣០១** គម្រោង ជាគម្រោងអាទិភាពខ្ពស់ ត្រូវការទុនចំនួន **៩៣៦** លានដុល្លារ។ គម្រោងវិនិយោគជាទុនចំនួន **៣៨៧** គម្រោង ត្រូវការទុន **២៤៤៤** លានដុល្លារ និងគម្រោងជំនួយបច្ចេកទេស ចំនួន **១៤៧** គម្រោង ត្រូវការទុន **៤០៥** លានដុល្លារ។ ជាសរុបសម្រាប់កម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២ ត្រូវការទុនចំនួន **២៨៥០** លានដុល្លារ ក្នុងនោះគឺ សម្រាប់ឆ្នាំ ២០១០ មានចំនួន **៩៤០** លានដុល្លារ ឆ្នាំ ២០១១ ចំនួន **៩៥០** លានដុល្លារ និងឆ្នាំ ២០១២ ចំនួន **៩៦០** លានដុល្លារ។ បរិមាណទុនសរុប **២៨៥០** លានដុល្លារ សម្រាប់កម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២ ក្នុងនោះបរិមាណទុនដែលបានសន្យាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍មានចំនួន **១៣៤២** លានដុល្លារ (ក្នុងនោះពីរាជរដ្ឋាភិបាលកម្ពុជាចំនួន **៣១១** លានដុល្លារ និងពីដៃគូអភិវឌ្ឍន៍ចំនួន **១០៣១** លានដុល្លារ) ដោយត្រូវការទុនបន្ថែមចំនួន **១៥០៧** **លានដុល្លារ**។

អង្គប្រជុំបានឯកភាពពិនិត្យ និងពិភាក្សាគ្នាយ៉ាងផុលផុសលើ សេចក្តីព្រាងនេះ៕



អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០១០-២០១២។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់

កាលពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ វេលាម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **ប៊ិច ឈុន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) និង ឯកឧត្តម **អ៊ុំ ប៊ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់** ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក អគ្គលេខាធិការ ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងក្រសួង–ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី។



ធនធានជលផលនៃព្រះរាជាណាចក្រកម្ពុជាដើរតួរនាទីយ៉ាងសំខាន់បំផុតក្នុងការផ្តល់នូវតម្រូវការប្រូតេអ៊ីន សាច់ត្រីសម្រាប់ប្រជាជនទូទាំងប្រទេស ជាក់ស្តែងប្រជាជនម្នាក់ៗបរិភោគសាច់ត្រីប្រមាណ **៥២.៤** គីឡូក្រាមក្នុងមួយឆ្នាំ តាមការស្រាវជ្រាវមានប្រភេទត្រីទឹកសាបជាង **៧០០** ប្រភេទ និងត្រីទឹកប្រៃជាង **៥០០** ប្រភេទ ត្រូវបានរកឃើញ ដែលនេះបញ្ជាក់ពីភាពសំបូរបែបនៃធនធានជលផលក្នុងប្រទេសកម្ពុជាយើង។ ទោះជាយ៉ាងនេះក្តី ដោយសារតែកំណើនប្រជាជនចេះតែកើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ ធ្វើឲ្យតម្រូវការត្រីក៏កាន់តែកើនឡើងដែរ ដែលនេះជាកត្តាបង្កឲ្យមានសកម្មភាពនេសាទហួសកំណត់ និងមានលក្ខណៈបំផ្លិចបំផ្លាញទៅលើធនធានជលផល។

មានសកម្មភាពផ្សេងៗទៀតជាច្រើន ដូចជា ការកាប់បំផ្លាញព្រៃលិចទឹក ការធ្វើសំណង់រូបវន្តនានាក្នុងដែននេសាទ និងការប្រើប្រាស់ថ្នាំគីមីសម្រាប់កសិកម្ម បាននឹងកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានទៅលើធនធានជលផលយ៉ាងធ្ងន់ធ្ងរ។ ជាក់ស្តែងប្រភេទវារិជាតិមួយចំនួន ជាពិសេសប្រភេទដែលមានទំហំធំ និងប្រភេទមានវដ្តជីវិតបន្តពូជវែង កំពុងតែទទួលរងការគំរាមគំហែង និងឈានទៅរកការបាត់បង់ពីដែនទឹកធម្មជាតិ។

ដើម្បីពង្រឹងការងារអភិរក្សធនធានជលផលប្រកបដោយនិរន្តភាព រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ ដើម្បីជំរុញការអនុវត្ត ការអភិរក្សធនធានជលផលឲ្យកាន់តែមានប្រសិទ្ធភាព។

អង្គប្រជុំបានឯកភាពពិនិត្យ និងពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្តីព្រាងនេះ ហើយបានផ្តល់អនុសាសន៍ថា៖ ការបំផ្លាញជំរកត្រី វដ្តជីវិត និងកន្លែងត្រីទំលាក់ពង ជាមូលហេតុនាំឲ្យប្រភេទមួយចំនួនជិតផុតពូជ។ ដូច្នេះ គួរដាក់ទិន្នន័យពាក់ព័ន្ធនេះនៅក្នុងឧបសម្ព័ន្ធ ដើម្បីជាមូលដ្ឋានធ្វើការការពារ អភិរក្សទល់នឹងការសម្បទានអភិវឌ្ឍន៍។ ក្រសួងសាមី បានឯកភាពទទួលយកអនុសាសន៍នេះ។

អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់។

## សេចក្ដីព្រាងអនុក្រឹត្យស្ដីពី

# ការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ



កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ វេលាម៉ោង ៨:៣០ នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំទី១ ក្រោមអធិបតីភាព ឯកឧត្តម **សំ សុខផល** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ និង ឯកឧត្តម **តឹម សយសាម៉ាឡែន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់អគារសហកម្មសិទ្ធិ ដោយមានការអញ្ជើញចូលរួមពីសំណាក់ តំណាងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក អគ្គលេខាធិការ ក.ស.វ. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញ ទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ ត្រង់ជំពូកទី ១០ (មាត្រា ១៧៥-១៨៥) បានចែងអំពី "សហកម្មសិទ្ធិ" ដែលក្នុងនោះមានចែងអំពីសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដោយកំណត់អំពីសិទ្ធិ និងកត្តាព្វកិច្ចរបស់សហកម្មសិទ្ធិករ លើចំណែកឯកជន និងលើចំណែករួម តែតម្រូវឲ្យមានការកំណត់ច្បាស់អំពីយន្តការ និងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិនេះ។ បន្ថែមលើនេះទៀត តាមមាត្រា ១១ នៃច្បាប់ភូមិបាលក៏តម្រូវឲ្យមានបទប្បញ្ញត្តិលំអិតកំណត់អំពីរបបផ្សេងៗ នៃកម្មសិទ្ធិ ដើម្បីឆ្លើយទៅនឹងការវិវឌ្ឍរបស់សង្គមខ្មែរ ពិសេសការកើនឡើងការអភិវឌ្ឍលើវិស័យសំណង់ ដែលមានការសាងសង់អគារធំៗ ខ្ពស់ៗ ជាប្រភេទអគារសហកម្មសិទ្ធិ។



អង្គប្រជុំបានឯកភាពពិនិត្យ និងពិភាក្សាគ្នាយ៉ាងផុលផុសលើសេចក្ដីព្រាងនេះ ហើយបានលើកជាបញ្ហាឡើងថា៖ សេចក្ដីព្រាងអនុក្រឹត្យនេះ ចំណុចគោលគឺ ការចុះបញ្ជី ដូច្នេះគួរបំបែកខ្លឹមសារជាពីរគឺ អនុក្រឹត្យស្ដីពីការចុះបញ្ជីសហកម្មសិទ្ធិ អចលនវត្ថុ និងច្បាប់ស្ដីពីការគ្រប់គ្រងនិងការប្រើប្រាស់អគារ សហកម្មសិទ្ធិ ឬរី និងសិទ្ធិជនបរទេស។ ក្រសួងសាមីនឹងបញ្ចូលពាក្យពលរដ្ឋខ្មែរទៅក្នុងអនុក្រឹត្យ ដើម្បីកុំឲ្យយល់ច្រឡំអនុវត្តលើជនបរទេស ហើយបានរក្សាចំណងជើងអនុក្រឹត្យទុកដដែល និងបានកែសម្រួលពាក្យពេចន៍ ឃ្លាឃ្លោងមួយចំនួន ឲ្យកាន់តែសុក្រឹត្យជាងមុន តាមស្មារតីនៃអង្គប្រជុំ៕

# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មីនា ឆ្នាំ ២០០៩



## ១) ស្ថានភាពថ្លៃ និងអត្រាប្តូរប្រាក់

ក្នុងខែ មីនា ឆ្នាំ ២០០៩នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ ធៀបនឹងខែមុនកើនឡើង ១.៣% (អតិផរណា ១.៣%) ប៉ុន្តែបើធៀបនឹងខែ មីនា ឆ្នាំ ២០០៨ (ក្នុងរយៈពេល១២ខែ) សន្ទស្សន៍នេះថយចុះ 0.៧%។ នេះបណ្តាលមកពីការប្រែប្រួលនៃសន្ទស្សន៍ថ្លៃក្រុមធំៗដូចខាងក្រោម៖







-ក្រុមម្ហូបអាហារបានកើនឡើង ១.៩% ធៀបនឹងខែមុន ប៉ុន្តែថយចុះ 0.៩% ក្នុងរយៈពេល ១២ខែ។ ក្នុងនោះ ៖

- ⋆ អង្ករ កើនឡើង ០.៤% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៩.៧% ក្នុងរយៈពេល១២ខែ
- ⋆ សាច់ជ្រូកស្រស់ កើនឡើង ០.៧% ធៀបនឹងខែមុនប៉ុន្តែថយចុះ ១៦% ក្នុងរយៈពេល ១២ខែ
- ⋆ សាច់គោស្រស់ កើនឡើង ២.៣% ធៀបនឹងខែមុន និងកើនឡើង ១២% ក្នុងរយៈពេល ១២ខែ
- ⋆ សាច់មាន់ស្រស់ កើនឡើង ៣.៨% ធៀបនឹងខែមុន និងកើនឡើង ៣.៧% ក្នុងរយៈពេល ១២ខែ
- ⋆ ត្រីស្រស់ កើនឡើង ៦.៥% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៨.៥% ក្នុងរយៈពេល ១២ខែ
- ⋆ ផ្លែឈើ កើនឡើង ១.០ ធៀបនឹងខែមុន និងកើនឡើង ១៤% ក្នុងរយៈពេល ១២ខែ
- ⋆ បន្លែ ថយចុះ ២.៣% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ១.២% ក្នុងរយៈពេល ១២ខែ

- ក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ កើនឡើង ១.៨% ធៀបនឹងខែមុននិងកើនឡើង ១៥% ក្នុងរយៈពេល ១២ខែ
- ក្រុមសំលៀកបំពាក់និងស្បែកជើង កើនឡើង ១.១% ធៀបនឹងខែមុន និងកើនឡើង ៦.៦% ក្នុងរយៈពេល១២ខែ
- ក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត កើនឡើង ០.៣% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៥% ក្នុងរយៈពេល ១២ខែ
- ក្រុមគ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ កើនឡើង ០.៦% ធៀបនឹងខែមុន និងកើនឡើង ៥.១% ក្នុងរយៈពេល ១២ខែ
- ក្រុមដឹកជញ្ជូន កើនឡើង ១.៥% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១៧% ក្នុងរយៈពេល ១២ខែ
  - ⋆ ថ្លៃប្រេងសាំង កើនឡើង ១.៩% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៣៤% ក្នុងរយៈពេល ១២ខែ
  - ⋆ ថ្លៃម៉ាស៊ូត ថយចុះ ២.៧% ធៀបនឹងខែមុន និងថយចុះ ៣៤% ស្មើនឹង ១៤៤៣រៀល/១លីត
- ក្រុមការសិក្សា កើនឡើង ៣.៩% ធៀបនឹងខែមុន និងកើនឡើង ២៥% ក្នុងរយៈពេល ១២ខែ
- ក្រុមទំនិញ និងសេវាកម្មផ្សេងៗ កើនឡើង ១.៣% ប៉ុន្តែថយចុះ ១.៣% ក្នុងរយៈពេល ១២ខែ។

**អត្រាប្តូរប្រាក់រៀល/ដុល្លារអាមេរិក** ស្មើនឹង ៤០៨៩រៀល/១ដុល្លារ ថយចុះ ០.៨% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២.៤% ក្នុងរយៈពេល ១២ខែ។ **អត្រាប្តូរប្រាក់រៀល/បាត** ស្មើនឹង ១១៥រៀល/១បាត កើនឡើង ០.៩% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ៩.៤% ក្នុងរយៈពេល ១២ខែ។

## ២) ស្ថានភាពហិរញ្ញវត្ថុ

**ចំណូលថវិកាជាតិ** ក្នុងខែ នមីនា ឆ្នាំ ២០០៩នេះ មានចំនួន ៤៤៤ពាន់លានរៀល កើនឡើង ២៦% ស្មើនឹង ៩១ពាន់លានរៀល ធៀបនឹងខែមុន ប៉ុន្តែថយចុះ ១០% ក្នុងរយៈពេល ១២ខែ។ ការកើនឡើងនៃចំណូលថវិការជាតិក្នុងខែនេះ គឺបណ្តាលមកពីចំណូលចរន្តកើនឡើង ២៦% ធៀបនឹងខែមុន។

**ចំណូលចរន្ត** ក្នុងខែ មីនានេះ មានចំនួន ៤៤៤ពាន់លានរៀល បើធៀបនឹងខែមុន កើនឡើង ២៧% ស្មើនឹង ៩១ពាន់លានរៀល ប៉ុន្តែថយចុះ ២% ក្នុងរយៈពេល ១២ខែ។ ក្នុងចំណូលចរន្តនេះ មានចំណូលសារពើពន្ធ ចំនួន ៣៩៩ ពាន់លានរៀល(១) បើធៀបនឹងខែមុន កើនឡើង ៤៥% ស្មើនឹង ១២៤ពាន់លានរៀល និងកើនឡើង ៤% ក្នុងរយៈពេល ១២ខែ និងចំណូលពុំមែនសារពើពន្ធ ៤៥ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ ៤០% ស្មើនឹង ៣០ពាន់លានរៀល និងថយចុះ ៣៥% ក្នុងរយៈពេល ១២ខែ។

**ចំណូលមូលធន** ពុំមានទេក្នុងខែនេះ (ខែមុនមាន ២.៨ពាន់លានរៀល)។

(១) នេះជាតួលេខរបស់អគ្គនាយកដ្ឋានរតនាគារជាតិ បើតាមតួលេខរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករវិញ ចំណូលសារពើពន្ធមានចំនួន ៤០៥ពាន់លានរៀល។

## សូចនាករមួយចំនួននៃថវិកាជាតិ ( ខែ មេសា ឆ្នាំ ២០០៩ )

| ល.រ | សូចនាករ | ឯកតា (ពាន់លានរៀល) | | បំរែបំរួល មេសា/ មីនា (%) | បំរែបំរួលរយៈពេល ១២ខែ (%) |
|---|---|---|---|---|---|
| | | មីនា | មេសា | | |
| ១ | ចំណូលថវិកាជាតិ | ៤៤៤ | ៤២០ | -៥ | -២៩ |
| ២ | ចំណូលមូលធន | ២.៤ | ០ | ២.៥ | -៩៨ |
| ៣ | អំណោយ | ០ | ០ | - | - |
| ៤ | ខ្ចីបុលក្រៅប្រទេស | ០ | ០ | - | - |
| ៥ | ចំណូលចរន្ត | ៤៤៤ | ៤១៧ | -៦ | -១១ |
| ៦ | ចំណូលសារពើពន្ធ* | ៣៩៩ | ៣៦៨ | -៨ | -៧ |
| ៧ | ពន្ធ និងអាករគយ* | ២១៥ | ២០៥ | -៥ | -២៤ |
| ៨ | ចំណូលពន្ធដារ* | ១៩០ | ១៨៨ | -១ | ៩ |
| ៩ | ចំណូលពុំមែនសារពើពន្ធ | ៤៥ | ៤៩ | ១០ | ៣៤ |
| ១០ | ចំណាយថវិកាជាតិ | ៤៣៩ | ៣៩៣ | -១០ | ៣២ |
| ១១ | ចំណាយមូលធន | ១០៣ | ៦០ | -៤២ | -៣១ |
| ១២ | ចំណាយចរន្ត | ៣៣៦ | ៣៣៣ | -១ | ៥៩ |
| ១៣ | តុល្យភាពថវិកាជាតិ | ៥ | ២៦ | ៤៨៧ | -៩១ |

* ទីនេះ ដោយសារប្រភពទិន្នន័យខុសគ្នា ធ្វើឲ្យផលបូកនៃពន្ធ និងអាករគយ (ប្រភពអគ្គនាយកដ្ឋានគយ និងរដ្ឋាករ) និងចំណូលពន្ធដារ (ប្រភពអគ្គនាយកដ្ឋានពន្ធដារ) មានលំអៀងពី តួលេខចំណូលសារពើពន្ធ ( ប្រភពអគ្គនាយកដ្ឋានរតនាគាជាតិ)។

### ៣) ស្ថានភាពរូបិយវត្ថុ

ក្នុងខែ មេសានេះ យើងពុំមានការវិភាគផ្នែកស្ថានភាពរូបិយវត្ថុទេ ដោយកង្វះទិន្នន័យដែលទទួលបានពីធនាគារជាតិ។

### ៤) ស្ថានភាពផលិតកម្ម

-កសិកម្ម: **ផលិតកម្មនេសាទ** នាខែ មេសានេះ មានចំនួន **៤១**ពាន់តោន ថយចុះ **១០%** បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង **១%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ផលិតកម្មកៅស៊ូ** ក្នុងខែ មេសា មានចំនួន **០.៩**ពាន់តោន កើនឡើង **១២៥%** បើធៀបនឹងខែមុន និងកើនឡើង **១៣%** ក្នុងរយៈពេល ១២ខែ។

- ឧស្សាហកម្ម: **ផលិតកម្មវាយនភ័ណ្ឌនិងស្បែកជើង**(២) ដែលកត់ត្រាបានក្នុងខែ មេសា មាន **៤២២** ពាន់លានរៀល ថយចុះ **១០%** បើធៀបនឹងខែមុន និងថយចុះ **៩%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រោងចក្រថ្មីដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នាខែ មេសានេះ មានចំនួន **៣**។ ឧស្សាហកម្មធុនតូច និងសិប្បកម្មដែលត្រូវបានអនុញ្ញាតដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទេ ក្នុងខែ មេសានេះ មានចំនួន **២០** ក្នុងនោះ បើកថ្មី **១៥** និងបន្ត **៥**។

(២) ដោយទិន្នន័យនៃផ្នែកនេះទទួលបានមិនគ្រប់ពីរោងចក្រដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា តួលេខនេះអាចមិនឆ្លុះបញ្ចាំងស្ថានភាពពិតនៃផលិតកម្មវាយនភ័ណ្ឌនិងស្បែកជើងឡើយ។

– សំណង់: **សំណង់ដែលអនុញ្ញាតឲ្យសាងសង់** នាខែ មេសានេះ សរុបមាន **៣១៥**ពាន់ ម² ថយចុះ **៨៧%** បើធៀបនឹងខែមុន និង–ថយចុះ **៩៦%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះមាន សំណង់សាធារណៈ **៥**ពាន់ម² លំនៅដ្ឋាន **២៧៦**ពាន់ម² ឧស្សាហកម្ម **៣**ពាន់ម² ពាណិជ្ជកម្ម **៨**ពាន់ម² ទេសចរណ៍ **២២**ពាន់ម² និងផ្សេងៗ **៥**ពាន់ម²។ ការអនុញ្ញាតឲ្យសាងសង់នាខែនេះ បើគិតជាទឹកប្រាក់មានចំនួន **៩៣**លានដុល្លារ បើធៀបនឹងខែមុន ថយចុះ **៨៦%** និងថយចុះ **៣៤%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។

– សេវាកម្ម: **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម** ក្នុងខែ មេសា មានចំនួន **១៦៩** និង**ត្រូវបានលុប ចេញពីបញ្ជីពាណិជ្ជកម្ម** មានចំនួន **៣**។

**ការដាក់ពាក្យរកការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ក្នុងខែ មេសា មានចំនួន **២២៧៦**នាក់។ ការងារទទួលបាន សរុបតាមរយៈក្រសួងការងារ និងក្រុមហ៊ុនមានចំនួន **១៥៦១**នាក់ ក្នុងនោះ ក្នុងប្រទេសមានចំនួន **៩២០**នាក់ និង ក្រៅប្រទេសមានចំនួន **៦៤១**នាក់។

**អ្នកដំណើរតាមផ្លូវអាកាស** ក្នុងខែ មេសានេះ មានចំនួន **២១៧**ពាន់នាក់ បើធៀបនឹងខែមុន ថយចុះ **១៦%** និងថយចុះ **១៤%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះអ្នកដំណើរក្នុងស្រុក មានចំនួន **១០**ពាន់នាក់ និងអ្នកដំណើរអន្តរជាតិ មានចំនួន **២០៧**ពាន់នាក់។

**ចំនួនទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជាសរុប** ក្នុងខែ មេសានេះ មានចំនួន **១៧៨**ពាន់នាក់ បើធៀបនឹងខែមុន ថយចុះ **១២%** ប៉ុន្តែកើនឡើង **២.៣%** ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ ទេសចរផ្លូវអាកាស មានចំនួន **៨៧**ពាន់នាក់ ផ្លូវគោកនិងផ្លូវទឹក **៧៦**ពាន់នាក់។

– វប្បធម៌: **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ក្នុងខែ មេសានេះ បានអនុញ្ញាតទិដ្ឋាការដល់ផលិតកម្មភាពយន្តចំនួន **៣៦**លេខ រីឯការសំដែងសិល្បៈអាជីព និងមហាជនមានចំនួន **៦៥០**លើក។ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ ក្នុងខែ មេសានេះ មានចំនួន **៤៩៨៣**នាក់ បើធៀបនឹងខែមុនថយចុះ **៤០%** និងថយចុះ **៤៧%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។

## ៥) ស្ថានភាពពាណិជ្ជកម្ម

ការនាំចូល ក្នុងខែ មេសា មានចំនួន **១៣២២**ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ **១៥%** ស្មើនឹង **២២៨**ពាន់លានរៀល និងថយចុះ **១៧%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការថយចុះចំពោះការនាំចូលមាន** អគ្គិសនី ៥០% ដែកសំណង់ ៥៦% ស៊ីម៉ង់ត៍ ៤៥% គ្រឿងអេឡិចត្រូនិច ៣២% % ត្រាក់ទ័រនិងគោយន្ត ៣% ស្រូវសាលី ៥៧% ផ្លែឈើនិងបន្លែ ២៤% ប្រេងឆា ៦៥% និងប៊ីចេង ៣៧%។ **រីឯការកើនឡើងចំពោះការនាំចូលមាន** ប្រេងឥន្ធនៈ ១៣% រថយន្ត ២% ម៉ូតូ ១៦% អង្ករ ៣១% ជីនិងថ្នាំកសិកម្ម ២២% សំលៀកបំពាក់ ១០% បារី ៥៩% ស្ករស ៤៣% ភេសជ្ជៈ ២៣% នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម ៦៩% និងនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ* ២០%។

ការនាំចេញ ក្នុងខែ មេសា មានចំនួន **៧៣៧**ពាន់លានរៀល បើធៀបនឹងខែមុន ថយចុះ **១៨%** ស្មើនឹង **៥៤**ពាន់លានរៀល ប៉ុន្តែកើនឡើង **៣%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការថយចុះនៃផលិតផលនាំចេញមាន** ផលិតផលឈើកែច្នៃ ២៤% ផលិតផលវាយនភ័ណ្ឌ និងស្បែកជើង ៦% អង្ករ ៩៤% ផលិតផលនេសាទ ៥៥% កៅស៊ូ ២៦% និងការនាំចេញក្នុងក្របខ័ណ្ឌវិនិយោគ* ៥%។

***ជញ្ជីងពាណិជ្ជកម្មកម្ពុជា*** *ក្នុងខែ មេសានេះ មានឱនភាពចំនួន* ***៥៨៥ពាន់លានរៀល***។

* តំលៃនាំចូល–នាំចេញពន្ធជាបន្ទុករដ្ឋ (ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករ)។

– ឧស្សាហកម្ម: **ផលិតកម្មវាយនភ័ណ្ឌនិងស្បែកជើង**(៣) ដែលកត់ត្រាបានក្នុងខែ មីនា មាន **៨៦៩ពាន់លានរៀល** ថយចុះ **២៣%** បើធៀបនឹងខែមុន និងថយចុះ **៣២%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រោងចក្រថ្មីដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពលនាខែ មីនា នេះមានចំនួន ៥។ ពុំមានឧស្សាហកម្មធុនតូច និងសិប្បកម្មដែលត្រូវបានអនុញ្ញាតដោយ ក្រសួងឧស្សាហកម្មរ៉ែ និងថាម–ពលទេ ក្នុងខែ មីនានេះ។

– សំណង់: **សំណង់ដែលសាងសង់** សំណង់ដែលសាងសង់នាខែ មីនា នេះសរុបមាន **២៣៤៩ពាន់ម²** កើនឡើង **៧៣៧%** បើធៀបនឹងខែមុនស្មើនឹង **២០៦៩ពាន់ម²** និងកើនឡើង **៣២៧%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះមាន សំណង់សាធារណៈ **១៧ពាន់ម²** លំនៅដ្ឋាន **១២៩ពាន់ម²** ឧស្សាហកម្ម **១៤ពាន់ម²** ពាណិជ្ជកម្ម **២១៧០ពាន់ម²** ទេសចរណ៍ **១០ពាន់ម²** និងផ្សេងៗ **១០ពាន់ម²**។ ការសាងសង់នាខែ មីនានេះ បើគិតជាទឹកប្រាក់មានចំនួន **៦៤៣លានដុល្លារ** បើធៀបនឹងខែមុន កើនឡើង **៥៨៨%** និងកើនឡើង **៤៩៩%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។

– សេវាកម្ម: **ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម** នៅក្រសួងពាណិជ្ជកម្មក្នុងខែ មីនា មានចំនួន **១៩០** និងត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្មមានចំនួន ២។

**ការដាក់ពាក្យរកការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ក្នុងខែ មីនា មានចំនួន **១១២៥នាក់**។ ការងារទទួលបានសរុបតាមរយៈក្រសួងការងារ និងក្រុមហ៊ុន មានចំនួន **៥២៣៨នាក់** ក្នុងនោះក្នុងប្រទេសមានចំនួន **៤២៧១នាក់** និងក្រៅប្រទេសមានចំនួន **៩៦៧នាក់**។

**អ្នកដំណើរតាមផ្លូវអាកាស** ក្នុងខែ មីនា នេះមានចំនួន **២៥៧ពាន់នាក់** បើធៀបនឹងខែមុន កើនឡើង ០.៤% ប៉ុន្តែថយចុះ **១៩%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះអ្នកដំណើរក្នុងស្រុក មានចំនួន **១៤ពាន់នាក់** និងអ្នកដំណើរអន្តរជាតិចំនួន **២៤៣ពាន់នាក់**។

**ចំនួនទេសចរមកដល់ព្រះរាជាណាចក្រកម្ពុជាសរុប** ក្នុងខែ មីនា នេះមានចំនួន **២០៣ពាន់នាក់** បើធៀបនឹងខែមុន កើនឡើង **១%** ប៉ុន្តែថយចុះ **១.៤%** ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ **ទេសចរផ្លូវអាកាស** មានចំនួន **១០៥ពាន់នាក់** **ផ្លូវគោកនិងផ្លូវទឹក** មានចំនួន **៨៨ពាន់នាក់** និង**ទេសចរវិលល្ងាច** មានចំនួន **១០ពាន់នាក់**។

– វប្បធម៌: **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ក្នុងខែ មីនានេះ បានអនុញ្ញាតទិដ្ឋាការដល់ផលិតកម្មភាពយន្តចំនួន **៣៧លេខ** រីឯការសំដែងសិល្បៈអាជីព និងមហាជន មានចំនួន **៤៣៧០លើក**។ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ ក្នុងខែ មីនា នេះមានចំនួន **៨៣០១នាក់** បើធៀបនឹងខែមុនថយចុះ **២៨%** និងថយចុះ **២២%** ធៀបនឹងខែដូចគ្នាឆ្នាំមុន។

## ៥) ស្ថានភាពពាណិជ្ជកម្ម

ការនាំចូល ក្នុងខែ មីនា មានចំនួន **១៥៤៩ពាន់លានរៀល** បើធៀបនឹងខែមុន កើនឡើង **៧៤%** ស្មើនឹង **៦៥៧ពាន់លានរៀល** និងកើនឡើង **៦.០%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើងចំពោះការនាំចូលមាន** អគ្គិសនី **១២៨%** ដែកសំណង់ **១១៤%** ស៊ីម៉ង់ត៍ **៤៤%** រថយន្ត **៦៤%** ម៉ូតូ **៨១%** ស្រូវសាលី **២៦៥%** ផ្លែឈើនិងបន្លែ **៥.៦%** ជីនិងថ្នាំកសិកម្ម **៣២%** សំលៀកបំពាក់ **៤៥%** ប្រេងឆា **៣៨%** ប៊ីចេង **៥៦%** នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម **៥៨%** និងនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ* **៥០%**។ **រីឯការថយចុះចំពោះការនាំចូលមាន** ប្រេងឥន្ទនៈ **៤%** ឧស្ម័ន **៤០%** គ្រឿងអេឡិចត្រូនិច **១%** គ្រាក់ទ័រនិងគោយន្ត **២៣%** អង្ករ **៧៧%** ស្ករស **៣៤%** ភេសជ្ជៈ **៣៣%** និងបារី **៤៨%** ។

ការនាំចេញ ក្នុងខែ មីនា មានចំនួន **៨៩៤ពាន់លានរៀល** បើធៀបនឹងខែមុន ថយចុះ **៩%** ស្មើនឹង **៨៩ពាន់លានរៀល** និងថយចុះ **៤.៣%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការថយចុះនៃផលិតផលនាំចេញមាន** ផលិតផលឈើកែច្នៃ **៣.៨%** ផលិតផលវាយនភ័ណ្ឌ និងស្បែកជើង **១៥%** កៅស៊ូ **៣៥%** និងការនាំចេញក្នុងក្របខ័ណ្ឌវិនិយោគ* **១៤%**។ រីឯការកើនឡើងមាន អង្ករ **៦៣%**។

**ជញ្ជីងពាណិជ្ជកម្មកម្ពុជា** ក្នុងខែ មីនា នេះមានឱនភាពចំនួន **៦៥៥ពាន់លានរៀល**។

(៣) ដោយទិន្នន័យនៃផ្នែកនេះទទួលបានមិនគ្រប់ពីរោងចក្រដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា តួលេខនេះអាចមិនឆ្លុះបញ្ចាំងស្ថានភាពពិតនៃផលិតកម្មវាយនភ័ណ្ឌនិងស្បែកជើងឡើយ។

* តំលៃនាំចូល–នាំចេញពន្ធជាបន្ទុករដ្ឋ (ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករ)

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មេសា ឆ្នាំ ២០០៩

| | | |
|---|---|---|
| ១ | ០២.០៤.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាង Nida និងក្រុមហ៊ុន ANANA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៣.០៤.០៩ | ចូលរួមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិសាជាថ្មីលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារ-ណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ស្តីពីការជម្រុញ និងការការពារវិនិយោគ។ |
| ៣ | ០៧.០៤.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីដាក់ឲ្យដំណើរការឧបករណ៍វិទ្យុនាំផ្លូវចតយន្តហោះ ILS នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដែលជាពិធីដ៏ឱឡារិកក្នុងការលើកកម្ពស់ និងនាធាសុវត្ថិភាពដល់ការចុះចតយន្តហោះនៅអាកាសយាន ដ្ឋានអន្តរជាតិសៀមរាប។ |
| ៤ | ១០,១២.០៤.០៩ | ចូលរួមជាកិត្តិយសក្នុងពិធីជូននិងទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ានពាក់ព័ន្ធ (កំពូលអាស៊ានបូក៣ កំពូលអាស៊ានបូក១ កំពូលអាស៊ីបូព៌ាលើកទី១៤ និងកំពូលអាស៊ាន អ.ស.ប.លើកទី១៣ នៅទីក្រុងប៉ាតាយ៉ា នៃព្រះរាជាណាចក្រថៃ។ |
| ៥ | ២៤.០៤.០៩ | ចូលរួមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច។<br>២-សេចក្តីព្រាងគោលនយោបាយស្តីពី ការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិច នៅព្រះរាជាណាចក្រកម្ពុជា។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។<br>៤-បញ្ហាផ្សេងៗ |
| ៦ | ២៩.០៤.០៩ | ចូលរួមក្នុងកិច្ចប្រជុំផ្ទៃក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម ទូច ស៊ាងតាណា សមាជិក ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មេសា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១-៨.០៤.០៩ | បេសកកម្មនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ក្នុងកិច្ចអភិរក្សសត្វផ្សោត និងអភិវឌ្ឍន៍សហគមន៍។ |
| ២ | ១៦-២៣.០៤.០៩ | បេសកកម្មនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ក្នុងកិច្ចអភិរក្សសត្វផ្សោត និងអភិវឌ្ឍន៍សហគមន៍។ |

## សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម គីម សយសាម៉ាឡែន សមាជិក ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មីនា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២-០៤-០៩ | ចូលរួមក្នុងពិធីចុះហត្ថលេខាលើ អនុស្សារណៈនៃការយោគយល់គ្នារវាង NiDA និង ក្រុមហ៊ុន ANANA ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១០-០៤-០៩ | ចូលរួមក្នុងពិធីបិទការប្រគួតប៊ូល និងប៉េតង់កម្ពុជាលើកទី ៣ ក្រោមអធិបតីភាព ឯកឧត្តម **តាវ សេងហួរ** |
| ៣ | ២៣-០៤-០៩ | ចូលរួមក្នុងពិធីចុះហត្ថលេខាប្រគល់ និងទទួលអំណោយសប្បុរសជន ជូនមូលនិធិបាយ័ន សម្រាប់កិច្ចការសង្គមកិច្ច ក្រោមអធិបតីភាព ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក |

## សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម ឆយ អួន សមាជិក ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មេសា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២-០៤-០៩ | ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ស៊ុំកូនអន្តរប្រទេស។ |
| ២ | ២៣-០៤-០៩ | ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើៈ<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម កែវ វិចិត្រ អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែ មេសា ឆ្នាំ ២០០៩

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១០-០៤-០៩ | ចូលរួមក្នុងអង្គប្រជុំក្រុមការងារដើម្បីពិភាក្សាលើករណីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្នើសុំកែសម្រួលលើជំពូក III មាត្រា ៦ នៃសេចក្តីព្រាងអនុក្រឹត្យស្តីពី និតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ |
| ២ | ២១-០៤-០៩ | ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ |

# ពិធីសូត្រមន្តរបស់ ក.ស.វ.





កាលពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩ នៅក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) នៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំពិធីសូត្រមន្តចម្រើនសិរីសួស្តីក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ ឆ្លូវ ឯកស័ក ពុទ្ធសករាជ ២៥៥៣ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម អនុប្រធាន អគ្គលេខាធិការ និង ឯកឧត្តម លោកជំទាវ សមាជិក នៃ ក.ស.វ. ព្រមទាំងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន ក្រោមអធិបតីភាព ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៕

# ព្រឹត្តិបត្រព័ត៌មាន

| | |
|---|---|
| naykRKbRKgTeTA 3 | Ék]tm Km sysamaELn smaCk k>s>v> |
| nBnnayk 3 | Ék]tm Ekv vcRt GKel xaFkar k>s>v> |
| GkvPaKesdkc 3 | Ék]tm mm sarT smaCkbRmg k>s>v> |
| nBnGtbT ngcatEcgTeTA 3 | Ék]tm eGg rtmn GKel xaFkarrg k>s>v> |
| TnakTng nge)aHBmpSay 3 | elak mk Fara CnykareTsrdm®nTTl bnkkargar k>s>v> |
| beckeTskBüTr 3 | elak sy vasa RbFankaryaly k>s>v> |
| ykBtman ngrbft 3 | elak ehg sP³bBaa RbFankaryaly k>s>v> |




ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

TrsB 023 211 943 / 016 307 330

Trsar 023 211 943

E-mail: veasna@live.in